# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ១
បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# អំណាចតុលាការនៅក្នុងច្បាប់កម្ពុជា


រៀបចំដោយៈ

-ឯកឧត្តម **សន សោភ័ណ** ឯកឧត្តម **ចាយ ច័ន្ទតារាវណ្ណ** និងឯកឧត្តម **ម៉ុន មុនីចរិយា**

នៅក្នុងការគ្រប់គ្រងរដ្ឋតាមបែប**“នីតិរដ្ឋ”**និង**“ប្រជាធិបតេយ្យ”**,អំណាចកំពូលទាំង៣ដែលតែងត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ រួមមាន **អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ** និង **អំណាចតុលាការ**។ ស្របតាមគោលការណ៍នៃការបែងចែកអំណាច សំដៅធានាបានតុល្យភាពនៃការប្រើប្រាស់អំណាចក្នុងការគ្រប់គ្រងរដ្ឋ, អំណាចកំពូលទាំង ៣ នេះ ត្រូវបានចែកដាច់ពីគ្នា និងមានឯករាជ្យភាពពីគ្នាទៅវិញទៅមក ដែលមានន័យថា អំណាចទាំង ៣ នេះ មិនចំណុះឱ្យគ្នាទៅវិញទៅមកនោះទេ ពោលគឺ អំណាចតុលាការមិនចំណុះឱ្យ ឬមិនស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់អំណាចនីតិប្បញ្ញត្តិឬអំណាចនីតិប្រតិបត្តិនិងបញ្ច្រាសមកវិញ។នៅក្នុងសង្គមនីតិរដ្ឋ, អំណាចតុលាការ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់, ការការពារប្រឆាំងនឹងការរំលោភបំពានដោយអយុត្តិធម៌ក្នុងសង្គម និងបានចូលរួមចំណែកក្នុងការធានាថែរក្សានូវសន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ដែលជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានអនុម័តនូវគោលការណ៍នៃការបែងចែកអំណាចនេះ ហើយអំណាចតុលាការត្រូវបានកំណត់នៅក្នុងជំពូកទី១១ ថ្មី នៃរដ្ឋធម្មនុញ្ញ។ ផ្អែកតាមមាត្រា១២៨ ថ្មី (មាត្រា១០៩ ចាស់) នៃរដ្ឋធម្មនុញ្ញ, អំណាចតុលាការ ជាអំណាចឯករាជ្យ ហើយអំណាចតុលាការធានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។តើអ្វីទៅជាអំណាចតុលាការ? តើស្ថាប័នណាជាអ្នកប្រតិបត្តិអំណាចតុលាការ? តើឯករាជ្យភាពនៃអំណាចតុលាការមានន័យដូចម្តេច និងត្រូវបានការពារដោយរបៀបណា?

ជាទ្រឹស្តី ពាក្យថាអំណាចតុលាការ អាចមានអត្ថន័យ ២ យ៉ាងគឺៈ **(១)**-អំណាចតុលាការ ក្នុងន័យស្ថាប័ន ដែលសំដៅដល់ស្ថាប័នតុលាការ និង **(២)**-អំណាចតុលាការ ក្នុងន័យជាសិទ្ធិអំណាចដែលសំដៅដល់អំណាចក្នុងការជម្រះក្តីផ្តល់យុត្តិធម៌។

## I- អំណាចតុលាការក្នុងន័យជាអង្គភាពតុលាការ

ក្នុងន័យស្ថាប័នអំណាចតុលាការ គឺជាអំណាចឯករាជ្យ ហើយគ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការនេះបានឡើយ[1]។ អំណាចតុលាការ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ការរៀបចំអង្គការតុលាការ ត្រូវកំណត់ក្នុងច្បាប់។

1. មាត្រា១៣០ ថ្មី (មាត្រា ១១១ ចាស់) នៃរដ្ឋធម្មនុញ្ញ។

បច្ចុប្បន្ន ការរៀបចំអង្គការតុលាការនៅកម្ពុជា ដែលជាសាលាជម្រះក្ដីទទួលបន្ទុកអនុវត្តនូវអំណាចតុលាការ (១) ត្រូវបានកំណត់នៅក្នុងច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤[2]។ ច្បាប់នេះ និងច្បាប់ផ្សេងទៀត ក៏កំណត់ផងដែរអំពីវិធានដើម្បីធានា និងការពារនូវឯករាជ្យភាពនៃអំណាចតុលាការ (២)។

## ១- សាលាជម្រះក្ដីជាស្ថាប័នដែលអនុវត្តអំណាចតុលាការ

ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ បានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមមាត្រា៤ នៃច្បាប់នេះ, សាលាជម្រះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់អនុវត្តអំណាចតុលាការ។ ផ្អែកតាមច្បាប់នេះ សាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជារួមមានៈ សាលាដំបូង, សាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាដំបូង ជាសាលាជម្រះក្ដីជាន់ទាប ហើយសាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្ដីជាន់ខ្ពស់។ សាលាដំបូង ត្រូវបានបង្កើតឡើងនៅគ្រប់រាជធានី-ខេត្ត។ ចំពោះសាលា ឧទ្ធរណ៍រួមមាន សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ដែលបច្ចុប្បន្នរួមមាន សាលាឧទ្ធរណ៍បាត់ដំបង, សាលាឧទ្ធរណ៍ព្រះសីហនុ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ដោយឡែក តុលាការកំពូល មានតែមួយគត់នៅរាជធានីភ្នំពេញ[3]។

យោងតាមមាត្រា១២៨ ថ្មី កថាខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញ អំណាចតុលាការ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ហើយផ្អែកតាមមាត្រា ៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, សាលាជម្រះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ។ ផ្អែកតាមបទប្បញ្ញត្តិទាំងនេះ មានតែសាលាជម្រះក្ដីទេដែលអនុវត្តអំណាចតុលាការ។ ប៉ុន្តែ នៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ មានអង្គការអយ្យការមួយផងដែរ។ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ក៏បានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដូច្នេះ បញ្ហាអាចចោទឡើងថា តើអង្គការអយ្យការជាផ្នែកមួយនៃអំណាចតុលាការដែរឬទេ? បើបកស្រាយតឹងរឹងតាមស្មារតីនៃមាត្រា១២៨ ថ្មីខាងលើ អំណាចតុលាការ ត្រូវប្រគល់ឱ្យតែតុលាការកំពូល

2. ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ត្រូវបានអនុម័តនៅឆ្នាំ ២០១៤ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។
3. ដើម្បីយល់ច្បាស់អំពីរចនាសម្ព័ន្ធអង្គការតុលាការនៅកម្ពុជា, សូមអានអត្ថបទបន្ទាប់របស់ ឯកឧត្តម សេង ឌីណា នៅក្នុងព្រឹត្តិប័ត្រនេះ ដែលសរសេរអំពីរចនាសម្ព័ន្ធតុលាការនៅកម្ពុជា។

និងសាលាជម្រះក្ដីប៉ុណ្ណោះ ពោលគឺ អង្គការអយ្យការមិនមែនជាស្ថាប័នអនុវត្តនូវអំណាចតុលាការនោះទេ។ ប៉ុន្តែ ផ្ទុយទៅវិញ អង្គការអយ្យការ និងព្រះរាជអាជ្ញា ក៏ត្រូវបានបញ្ញត្តនៅក្នុងមាត្រា ១៣១ថ្មី (មាត្រា១១២ចាស់), មាត្រា១៣៤ថ្មី (មាត្រា១១៥ចាស់) និងមាត្រា១៣៥ថ្មី (មាត្រា ១១៦ចាស់) ក្រោមជំពូកទី១១ ថ្មី ស្ដីពីអំណាចតុលាការផងដែរ។ មាត្រា១៣១ថ្មីនេះ កំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ មាត្រា១៣២ថ្មី (មាត្រា១១៣ចាស់) បានកំណត់ថា ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសំណើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្ដីទាំងអស់។បន្ថែមពីនេះឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមមានមុខងារក្នុងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញាផងដែរ។ ប្រសិនបើអង្គការអយ្យការ ជាផ្នែកមួយនៃអំណាចតុលាការដែលជាអំណាចឯករាជ្យ នោះអង្គការអយ្យការក៏គួរត្រូវបានកំណត់ថា ជាអំណាចឯករាជ្យ ដូចនឹងសាលាជម្រះក្ដីផងដែរ។

ប៉ុន្តែជាក់ស្ដែងអង្គការអយ្យការ គឺជាតំណាងឱ្យអំណាចសាធារណៈដែលធ្វើបណ្ដឹងអាជ្ញានិងសុំឱ្យអនុវត្តច្បាប់ ដើម្បីការពារផលប្រយោជន៍សាធារណៈ។ ផ្អែកតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, អង្គការអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ នៅតាមអយ្យការអមសាលាដំបូងរាជធានី-ខេត្តព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននិងមានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឱ្យចោទ ប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។ ដូចគ្នាផងដែរចំពោះ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្ដីជាន់ខ្ពស់[4] ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់[5]។ទន្ទឹមនេះការតែងតាំង ការផ្លាស់ប្ដូរ ការផ្ដាច់ពីមុខងារ ការដាក់តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាចាំបាច់ជាមួយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម

4. មាត្រា៣១, មាត្រា៥១ និងមាត្រា៧០ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ។
5. មាត្រា៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤។

ជាអ្នកលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ។ ក្នុងន័យនេះ អង្គការអយ្យការមិនមែនជាអំណាចឯករាជ្យនោះទេ តែជាអំណាចដែលស្ថិតក្រោមឋានានុក្រមច្បាស់លាស់ និងជាតំណាងឱ្យអំណាចសាធារណៈក្នុងការការពារផលប្រយោជន៍សាធារណៈ។ នៅបណ្តាប្រទេសផ្សេងៗអង្គការអយ្យការក៏មិនមែនជាអំណាចឯករាជ្យដែរ ដូចជាករណីនៅប្រទេសបារាំង ប្រទេសជប៉ុន និងប្រទេសកូរ៉េជាដើមដែលអយ្យការស្ថិតក្រោមឋានានុក្រមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មាត្រា១២៨ថ្មីកថាខណ្ឌទី៣នៃរដ្ឋធម្មនុញ្ញនិងមាត្រា៤នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការបានកំណត់ថា អំណាចតុលាការ គ្របដណ្តប់លើរឿងក្តីទាំងអស់រួមទាំងរឿងក្តី រដ្ឋបាលផងដែរ។ ដោយអំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់,តើការបង្កើតឡើងនូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយស្ថាប័ននីតិប្រតិបត្តិ(ការសម្រុះសម្រួលឬការផ្សះផ្សាវិវាទ)ឬយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានសិទ្ធិសម្រេចក្តីតាមវិធីកាត់ក្តីដោយផ្អែកទាំងលើអង្គហេតុ និងអង្គច្បាប់ (អាជ្ញាកណ្តាល ឬមជ្ឈត្តការ) អាចត្រូវចាត់ទុកថាជាការរំលោភបំពានលើអំណាចតុលាការដែរឬទេ? ចំពោះបញ្ហានេះ យើងអាចគូសបញ្ជាក់បានថា ទោះបីអំណាចតុលាការគ្របដណ្តប់លើគ្រប់រឿងក្តីទាំងអស់ក៏ដោយ ប៉ុន្តែមិនមែនមានន័យថា ច្បាប់បង្ខំឱ្យភាគីវិវាទ ត្រូវតែប្តឹងទៅតុលាការដើម្បីដោះស្រាយវិវាទរបស់ខ្លួននោះទេ។ ការសម្រេចប្តឹង ឬមិនប្តឹងទៅតុលាការ ឬការសម្រេចចិត្តស្វែងរកការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ គឺជាសិទ្ធិសម្រេចរបស់ភាគីវិវាទ លើកលែងតែចំពោះបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់កំណត់ថាមិនអាចជាកម្មវត្ថុនៃការសម្រុះសម្រួលបញ្ចប់ក្រៅប្រព័ន្ធតុលាការតែប៉ុណ្ណោះ។ លើការជាក់ស្តែង ការស្វែងរកដំណោះស្រាយចំពោះវិវាទ តាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមនិងបានរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ចប់វិវាទបានឆាប់រហ័សព្រមទាំងអាចជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តីផងដែរ។

## ២- ការធានាការពារឯករាជ្យភាពនៃអំណាចតុលាការ

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ នៅប្រទេសបារាំង ផ្អែកតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៨ ប្រធានាធិបតីបារាំងដែលជាប្រមុខរដ្ឋក៏បំពេញតួនាទីជាអ្នកធានាឯករាជ្យនៃអាជ្ញាធរតុលាការ

ដោយមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយប្រធានាធិបតីក្នុងការងារនេះផងដែរ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្ដូរ ការផ្ដាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា និងដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា។ មុខងារទាំងនេះ ជាមុខងារដ៏សំខាន់ក្នុងការធានានូវឯករាជ្យភាពនៃអំណាចតុលាការ។ ចៅក្រម ព្រះរាជអាជ្ញាទាំងអស់ ដែលប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការអនុវត្តនូវមុខងាររបស់ខ្លួន អាចត្រូវស្ថិតក្រោមការសម្រេចដាក់វិន័យដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងករណីរកឃើញកំហុស ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់ទណ្ឌកម្មវិន័យ ដូចមានចែងក្នុងច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។ សេចក្ដីសម្រេចនេះ ត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យនិងសម្រេច។សេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។ប៉ុន្តែការសម្រេចអំពីទណ្ឌកម្មវិន័យនេះមិនរារាំងការចោទប្រកាន់តាមផ្លូវតុលាការនោះទេ ប្រសិនបើចៅក្រម ឬព្រះរាជអាជ្ញា បានប្រព្រឹត្តបទល្មើសណាមួយ។

ក្រៅពីមុខងារទាំងនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសមត្ថកិច្ចផ្សេងទៀតផងដែរ ដែលរួមមានការផ្ដល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិ ឬចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ តាមបែបបទ និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការពិគ្រោះយោបល់ជាចាំបាច់ដើម្បីផ្ដល់យោបល់លើសេចក្ដីស្នើច្បាប់ ឬសេចក្ដីព្រាងច្បាប់ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ។

## II- អំណាចតុលាការក្នុងន័យជាអំណាចក្នុងការជម្រះក្ដីផ្ដល់យុត្តិធម៌

ក្នុងន័យទី២ អំណាចតុលាការ សំដៅដល់អំណាចក្នុងការជម្រះក្ដីផ្ដល់យុត្តិធម៌ជូនភាគីវិវាទ។ មាត្រា១២៨ថ្មី កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ បានកំណត់ថា អំណាចតុលាការ គ្របដណ្ដប់លើរឿងក្ដីទាំងអស់រួមទាំងរឿងក្ដីរដ្ឋបាលផងដែរ។ ដោយបច្ចុប្បន្ន កម្ពុជាមិនទាន់មានតុលាការរដ្ឋបាល, រឿងក្ដីរដ្ឋបាលទាំងអស់ ត្រូវស្ថិតក្រោមសមត្ថកិច្ច

ជំនុំជម្រះរបស់តុលាការរដ្ឋប្បវេណីដែលជាតុលាការនៃនីតិរួម។ មាត្រា១២៩ ថ្មី (មាត្រា១១០ ចាស់) កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តថា មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី (១)។ ក្នុងការជម្រះក្តីនេះ ចៅក្រមមានកាតព្វកិច្ចក្នុងការអនុវត្តនូវមុខងាររបស់ខ្លួនដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ដើម្បីធានានូវឯករាជ្យភាពរបស់ចៅក្រមក្នុងការសម្រេចក្តី, ច្បាប់បានផ្តល់ឱ្យចៅក្រមនូវអំណាចឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ។ ប៉ុន្តែ ការបំពាននឹងឆន្ទានុសិទ្ធិដោយខុសនឹងក្រមសីលធម៌ ឬខុសច្បាប់ ចៅក្រមអាចនឹងត្រូវប្រឈមមុខទាំងទណ្ឌកម្មខាងវិន័យ ទាំងទោសទណ្ឌផ្សេងទៀត ស្របតាមការកំណត់របស់ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន (២)។

## ១- សិទ្ធិជម្រះក្តីរបស់ចៅក្រម និងឯករាជ្យភាពរបស់ចៅក្រម

មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយឯករាជ្យ ដោយគោរពតាមច្បាប់ យ៉ាងម៉ត់ចត់ និងឱ្យអស់ពីដួងចិត្តនិងសតិសម្បជញ្ញៈរបស់ខ្លួន[6]។ ចៅក្រមទាំងឡាយ ត្រូវសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តីឬពីបុគ្គលណាមួយឡើយ[7]។ចៅក្រមត្រូវច្រានចោលនូវការប៉ុនប៉ងទាំងឡាយណាដែលធ្វើឱ្យមានឥទ្ធិពលដល់ការវិនិច្ឆ័យសេចក្តីរបស់ខ្លួន។ ប្រធានសាលាជម្រះក្តីនីមួយៗ មិនមានអំណាចឋានានុក្រមលើការជម្រះក្តីរបស់ចៅក្រមក្នុងដែនសមត្ថកិច្ចរបស់ខ្លួននោះទេ។ ប្រធានសាលាជម្រះក្តីមានត្រឹមតែអំណាចឋានានុក្រមផ្នែករដ្ឋបាលលើចៅក្រមតែប៉ុណ្ណោះ។

ក្នុងការជម្រះក្តី ចៅក្រមត្រូវស្វែងយល់ឱ្យបានច្បាស់អំពីអង្គហេតុ និងអង្គច្បាប់ មុននឹងធ្វើការសម្រេចសេចក្តីចំពោះសំណុំរឿងនីមួយៗ។សេចក្តីសម្រេចរបស់តុលាការ ត្រូវតែមានសំអាងហេតុ។ ចៅក្រមប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការវាយតម្លៃអំពីអង្គហេតុ និងក្នុងការបកស្រាយច្បាប់ ក្នុងករណីដែលច្បាប់ចែងមិនច្បាស់។ ឆន្ទានុសិទ្ធិនេះគឺជាអំណាចដែលប្រគល់ឱ្យចៅក្រម អាចជ្រើសរើស យកមធ្យោបាយណាមួយ តាមការវាយតម្លៃរបស់ខ្លួន

6. មាត្រា៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

7. មាត្រា៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា។

ដើម្បីដោះស្រាយបញ្ហាណាមួយ[8]។ ជារឿយៗ ច្បាប់តែងផ្តល់សិទ្ធិក្នុងការវាយតម្លៃដោយឆន្ទានុសិទ្ធិនេះឱ្យទៅចៅក្រមដើម្បីអាចផ្តល់នូវដំណោះស្រាយទៅតាមករណីជាក់ស្តែងនីមួយៗ។ ការវាយតម្លៃដោយឆន្ទានុសិទ្ធិនេះខុសពីការបកស្រាយច្បាប់។ក្នុងការជម្រះក្តី ចៅក្រមនៃបណ្តាសាលាជម្រះក្តីមានស្វ័យភាពក្នុងការបកស្រាយច្បាប់។ ផ្អែកតាមគោលការណ៍ស្វ័យភាពយុត្តាធិការ, ការបកស្រាយរបស់ចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់ មិនមានអានុភាពចាប់បង្ខំឱ្យចៅក្រមនៃសាលាជម្រះក្តីជាន់ទាប ត្រូវតែគោរពតាមនោះទេ លើកលែងតែចំពោះការសម្រេចអំពីវិវាទច្បាប់ដែលធ្វើឡើងដោយសភារួមក្រុមរបស់តុលាការកំពូល ដែលជាការសម្រេចបិទផ្លូវតវ៉ា។ ប៉ុន្តែលើការជាក់ស្តែងការមិនគោរពតាមការបកស្រាយច្បាប់របស់តុលាការកំពូលអាចធ្វើឱ្យសាលក្រមរបស់សាលាដំបូង ឬសាលដីការបស់សាលាឧទ្ធរណ៍ ត្រូវបានបដិសេធដោយតុលាការកំពូល[9]។ ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ចែងមិនច្បាស់ ឬច្បាប់មិនបានចែង ចៅក្រមត្រូវជំនុំជម្រះ ដោយផ្អែកតាមទំនៀមទំលាប់ ប្រពៃណី វិចារណញ្ញាណ ឬសមធម៌[10]។

## ២- ដែនកំណត់នៃឯករាជ្យភាព និងឆន្ទានុសិទ្ធិរបស់ចៅក្រម

ទោះបីចៅក្រម មានឯករាជ្យភាព និងឆន្ទានុសិទ្ធិក្នុងការជម្រះក្តីក៏ដោយ, ប៉ុន្តែ ចៅក្រមត្រូវគោរពច្បាប់ឱ្យបានម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ទន្ទឹមនេះ ចៅក្រមត្រូវគោរពនូវក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការបំពេញមុខងាររបស់ខ្លួន។ ក្រមសីលធម៌របស់ចៅក្រមនិងព្រះរាជអាជ្ញាមានគោលបំណងពង្រឹងនូវឯករាជ្យភាពនិងសេចក្តីថ្លៃថ្នូររបស់អង្គចៅក្រមក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន សំដៅលើកកម្ពស់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ និងកេរ្តិ៍ឈ្មោះរបស់ចៅក្រម។ ក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញានេះ បានកំណត់នូវគោលការណ៍ដែលអង្គចៅក្រមត្រូវប្រតិបត្តិតាម និងត្រូវចៀសវាង។ ផ្អែកតាមក្រមសីលធម៌នេះ, ក្នុងពេលបំពេញមុខងារ ចៅក្រមត្រូវប្រកាន់ខ្ជាប់នូវសុគតិធម៌ទាំង៥ រួមមាន ***វិរិយសម្បយុត្ត*** (ការបំពេញកិច្ច ប្រកបដោយវិរិយភាព), ***សុចរិតយុត្តិធម៌*** (ភាពទៀងត្រង់ និងយុត្តិធម៌), ***បញ្ញត្តិគារវោ*** (ការប្រតិបត្តិតាមច្បាប់ឱ្យបានម៉ឺងម៉ាត់), ***សមទណ្ឌោ*** (សមភាពនៃទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា) និង **បញ្ញាវុធវិនិច្ឆ័យ** (ការសម្រេចសេចក្តីប្រកបដោយ

---

8. សទ្ទានុក្រមពាក្យច្បាប់ដែលរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ទំព័រទី ១០។
9. ញាន វណ្ណៈ, មូលដ្ឋានគ្រឹះនៃភាពជាអ្នកច្បាប់៖ បច្ចេកទេសគតិយុត្ត, ឆ្នាំ ២០១៤ ទំព័រ ២៥
10. មាត្រា៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ ១៩៩៣។

បញ្ញា និងភាពឆ្លាតវៃ) និងត្រូវវៀចាកនូវអគតិធម៌ទាំង ៤ គឺ ***ឆន្ទាគតិ*** (លំអៀងព្រោះស្រលាញ់), ***ទោសាគតិ*** (លំអៀងព្រោះទោសៈ ឬស្អប់), ***ភយាគតិ*** (លំអៀងព្រោះភ័យខ្លាច) និង ***មោហាគតិ*** (លំអៀងព្រោះមោហៈ ល្ងង់ ឬអវិជ្ជា)។

ផ្អែកតាមមាត្រា ៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, ជាគោលការណ៍ ចៅក្រម និងព្រះរាជអាជ្ញា មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬផ្អែករដ្ឋប្បវេណី ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាចៅក្រម ឬព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែ គោលការណ៍នេះ មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញា ប្រើប្រាស់ការសម្រេចរបស់ខ្លួនដោយរំលោភបំពានធ្ងន់ធ្ងរក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ច និងមុខងារដែលច្បាប់ប្រគល់ឱ្យ។ ក្នុងន័យនេះ ការរំលោភអំណាច ឬការប្រព្រឹត្តខុសច្បាប់របស់ចៅក្រម ឬការប្រើឆន្ទានុសិទ្ធិរបស់ចៅក្រមដោយបំពាន គឺជាកំហុសដែលអាចត្រូវប្រឈមទាំងទណ្ឌកម្មខាងវិន័យ ទាំងទណ្ឌកម្មព្រហ្មទណ្ឌ និងទណ្ឌកម្មផ្អែករដ្ឋប្បវេណីផ្សេងទៀត តាមការកំណត់របស់ច្បាប់ជាធរមាន និងតាមអង្គហេតុជាក់ស្តែង។

ពាក្យបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬនៅក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់ឱ្យពិនិត្យ និងស្រាវជ្រាវបឋមលើពាក្យបណ្តឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងបញ្ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត។ បន្ទាប់ពីទទួលបានសំណុំរឿងវិន័យក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាវិន័យ អាចចាត់ឱ្យមានការស៊ើបអង្កេត និងស្រាវជ្រាវបន្ថែមដោយប្រើយន្តការក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងករណីរកឃើញកំហុស ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា។សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យនិងសម្រេច។សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។